ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៥ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន:

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I- ទីស្តីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

០២-២-១៩៩៥ -អនុក្រឹត្យលេខ ២៩ អនក្រ ស្តីពីការបង្កើតគណៈកម្មការទំនាក់ទំនងការងារជាមួយគងយោធពលភូមិន្ទថៃ ១៩៤

០៨-២-១៩៩៥ -អនុក្រឹត្យលេខ ៣០ អនក្រ ស្តីពីការបង្កើតគណៈកម្មាធិការផណាទានសំរាប់អភិវឌ្ឍន៏ជនបទ ១៩៦

០៨-២-១៩៩៥ -អនុក្រឹត្យលេខ ៣១ អនក្រ ស្តីពីការបំពេញបន្ថែមក្នុងប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិកកម្មករ ប្រចាំឆ្នាំ ១៩៩៥ .... ១៩៩

០៧-២-១៩៩៥ -អនុក្រឹត្យលេខ ១៤ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០០

២- សេចក្តីសំរេច

០២-២-១៩៩៥ -សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំកីឡាជនពិការកម្ពុជា ២០២

០៨-២-១៩៩៥ - សេចក្តីសំរេចលេខ ១៦ សសរ ស្តីពីការផ្ទេរសិទ្ធិ ២០៣

០៨-២-១៩៩៥ -សេចក្តីសំរេចលេខ ១៧ សសរ ស្តីពីការបង្កើតគណៈកម្មការចំនុះ សំរាប់កិច្ចសហប្រតិបត្តិការខ្មែរ ថៃ ២០៤

II- ការងារបណ្តាក្រសួង

១. ធីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ

ប្រកាស

០៥-២-១៩៩៥ -ប្រកាសលេខ ០០៦ ប្រ.សហវ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥ .... ២០៧

០៨-២-១៩៩៥ - សេចក្តីប្រកាសអន្តរក្រសួងលេខ ០៩១ ប្រក ស្តីពីការអនុញ្ញាតអោយ សាធារណជនដូរក្រដាសប្រាក់រៀលដែលចរាចរមិនកើត ២១៤

២. ធីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០២-២-១៩៩៥ - ប្រកាសលេខ ១១២ បឈ.ប្រក ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ២១៦

I - ឧីស្តីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២៩ អនក្រ
ស្តីពីការបង្កើតគណៈកម្មការធំនាក់ធំនង
ការងារជាមួយកងយោធពលភូមិន្ទ ថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខធានា សុវត្ថិភាព នៅតាមព្រំដែន កម្ពុជា_ថៃ
- តាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការមួយ ដើម្បីទំនាក់ទំនងការងារជាមួយ កងយោធពលភូមិន្ទថៃ ចំណុះការដឹកនាំ ផ្ទាល់របស់ សម្តេចនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ និងជាសហអគ្គមេបញ្ជាការ នៃ កងយោធពលខេមរភូមិន្ទ ដែលរួមមានសមាសភាពដូចខាងក្រោម :

១_ឯកឧត្តម ឧត្តមសេនីយ៍ឯក **ទៀ បាញ់** រដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាសហប្រធាន

២_ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជា ចំរាក់** រដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាសហប្រធាន

៣_ឯកឧត្តម ឧត្តមសេនីយ៍ឯក **ប៉ុល សារឿន** នាយរងអគ្គសេនាធិការ ជាអនុប្រធាន

៤_ឯកឧត្តម អ៊ុច ស៊ាន អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៥_លោកឧត្តមសេនីយ៍ ចំរើន ជាតិ មេបញ្ជាការការពារព្រំដែន ជាសមាជិក

៦_លោកឧត្តមសេនីយ៍ ជា សុគ្គា នាយកនិយាល័យទី ២ អសធ ជាសមាជិក

៧_លោកឧត្តមសេនីយ៍ ឈុំ សុជាតិ នាយក្រុមស្រាវជ្រាវ អសធ ជាសមាជិក

៨_លោកឧត្តមសេនីយ៍ ឡាយ ម៉ិនសុខ នាយកនាយកដ្ឋានទាក់ទងអន្តរជាតិ ជាសមាជិក

៩_លោកឧត្តមសេនីយ៍ ស៊ិក ឌី មេបញ្ជាការយោធភូមិភាគទី ៣ ជាសមាជិក

១០_លោកឧត្តមសេនីយ៍ ជួប សុខុន មេបញ្ជាការរងយោធភូមិភាគទី ៥ ជាសមាជិក

១១_លោកឧត្តមសេនីយ៍ ខាន់ សារឿន មេបញ្ជាការយោធភូមិភាគទី ៤ ជាសមាជិក

១២_លោកឧត្តមសេនីយ៍ អ៊ុច សំខាន់ មេបញ្ជាការកងនាវាចរខេមរភូមិន្ទ ជាសមាជិក

១៣_អ្នកអង្គម្ចាស់ឧត្តមសេនីយ៍ នរោត្តម ចក្រ ចក្រពង្ស មេបញ្ជាការកងអាកាសចរខេមរភូមិន្ទ ជាសមាជិក

មាត្រា ២ : ចាត់តាំងគណៈអចិន្ត្រៃយ៍សំរាប់ជំនួយដល់គណៈកម្មការសំរាប់ដោះស្រាយការងារប្រចាំថ្ងៃ ដែលរួមមានសមាសភាពដូចខាងក្រោម :

១_ឯកឧត្តម ឧត្តមសេនីយឯក ប៉ុល សារឿន ជាប្រធាន

២_លោក ឧត្តមសេនីយ៍ ចំរើន ជាតិ ជាសមាជិកអចិន្ត្រៃយ៍

៣_លោក ឧត្តមសេនីយ៍ ជា សុគ្គា ជាសមាជិកអចិន្ត្រៃយ៍

៤_លោក ឧត្តមសេនីយ៍ ឈុំ សុជាតិ ជាសមាជិកអចិន្ត្រៃយ៍

៥_លោក ឧត្តមសេនីយ៍ ប្រាក់ ម៉ារឌី ជាសមាជិក

៦_លោក ឧត្តមសេនីយ៍ ឡាយ ម៉ិនសុខ ជាសមាជិក

៧_លោក ឧត្តមសេនីយ៍ កែវ ឈួន ជាសមាជិក

៨_លោក ឧត្តមសេនីយ៍ យ៉ឹម សាធី ជាសមាជិក

៩_លោក វរសេនីយ៍ ឈួន ចំនួនឆាយា ជាសមាជិក

មាត្រា ៣ : ដើម្បីជំនួយដល់គណៈកម្មការនេះក្នុងការសហការដោះស្រាយការងារបានល្អ នៅតាមភូមិសាស្ត្រនិមួយៗ ចាំបាច់ត្រូវរៀបចំអនុគណៈកម្មការនិងក្រុមការងារមួយចំនួនប្រចាំការតាមបណ្តាទិស

នៃយោធភូមិភាគនិមួយៗ ។ ចំពោះសមាសភាពនិងភារកិច្ចរបស់អនុគណៈកម្មការ និងក្រុមការងារនិមួយៗ អាស្រ័យដោយ គណៈកម្មការជាអ្នករៀបចំ និងកំណត់ជាក់ស្តែង ។

មាត្រា ៤ : គណៈកម្មការនេះមានភារកិច្ចសហការជាមួយកងយោធពលភូមិន្ទថៃ ដើម្បីពិគ្រោះគ្នាដោះស្រាយអោយបានល្អ នូវរាល់បាតុភាព ឧប្បត្តិហេតុផ្សេងៗដែលកើតឡើងនៅតាមព្រំដែន កម្ពុជា-ថៃ បង្កើតឡើងនូវបរិយាកាស សន្តិសុខ សុវត្ថិភាព នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ។

មាត្រា ៥ : ទីកន្លែងធ្វើការរបស់គណៈអចិន្ត្រៃយ៍ នៃ គណៈកម្មការកំណត់យកទីបញ្ជាការដ្ឋានការពារព្រំដែនអគ្គសេនាធិការ ។

មាត្រា ៦ : គណៈកម្មការមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។
គណៈអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

មាត្រា ៧ : ចាត់ទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ១៦ មករា ១៩៩៥ ។

មាត្រា ៨ : ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ និង សាមីជនដែលមានឈ្មោះក្នុងប្រការ ១និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៩ : អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣០ អនក្រ
ស្តីពីការបង្កើតគណៈកម្មាធិការជំណាធាន
សំរាប់អភិវឌ្ឍន៍ជនបទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យត្រាស់បង្គាប់អោយកែសំរួលសមាសភាពរាជរដ្ឋាភិបាល លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសអោយប្រើជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការផលទានសំរាប់អភិវឌ្ឍន៍ជនបទ ដែលមានអក្សរកាត់ " គជទាន " ភ្ជាប់ជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ហើយមានទីតាំងនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : គជទានមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ហុង ស៊ុនហួត** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ	ជាប្រធាន
២-ឯកឧត្តម **ឈា សុខ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ជាអនុប្រធាន
៣-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ជាសមាជិក
៤-តំណាងអង្គការមិនមែនរដ្ឋាភិបាល បីនាក់	ជាសមាជិក
៥-តំណាងធនាគារជាតិនៃកម្ពុជា	ជាសមាជិក

៦-ឯកឧត្តម **ជា វ៉ាន់ឌេត** ទីប្រឹក្សាទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គលេខាធិការនៃគជទាន ហើយនឹងជានាយករបស់អង្គភាពបច្ចេកទេសអចិន្ត្រៃយ៍ ដែលមានភារកិច្ចជួយការងារទូទៅ និងការងារប្រចាំថ្ងៃ របស់ គជទាន ។

សមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន គជទាន ។ ក្នុងករណីចាំបាច់គជទានអាច អញ្ជើញតំណាងក្រសួងនានា ដែលពាក់ព័ន្ធចូលរួមប្រជុំ ។

សមាជិកទាំងអស់មានសំលេងស្មើគ្នាក្នុងអង្គប្រជុំ ។ ក្នុងករណីមានសំលេងស្មើគ្នា សំលេងប្រធានអង្គប្រជុំជា សំលេងមានឧត្តមភាព ។

មាត្រា ៣ : អង្គភាពបច្ចេកទេសមួយត្រូវបានបង្កើតឡើង ដើម្បីជាសេនាធិការ គជទាន ។ អង្គភាពបច្ចេកទេសនេះត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកនាយកអង្គភាព ។

អង្គភាពអាចទទួលជំនួយបច្ចេកទេស និង ជំនួយផ្សេងៗទៀតពីអង្គការជាតិ និងអន្តរជាតិ ដើម្បីជួយដល់ដំណើរការ នៃការងាររបស់ខ្លួន ។

មាត្រា ៤ : គជទាន មានភារកិច្ចដូចតទៅ:

ក-លើកឡើងនូវយុទ្ធសាស្រ្តអភិវឌ្ឍន៍ឥណទានជនបទជូនរាជរដ្ឋាភិបាលដោយ:

-រៀបចំក្របខ័ណ្ឌនិតិសាស្រ្តសំរាប់អនុវត្តនយោបាយជាតិក្នុងវិស័យសន្សំសំចៃ និង ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ និង កសិកម្ម ។

-កំណត់នយោបាយនៃការសន្សំសំចៃ និង ឥណទាន ហើយនិងក្របខ័ណ្ឌនិតិវិធីអោយស្រប និងលក្ខណៈពិសេសរបស់ឥណទានជនបទ ។

-ទទួលរៀបចំឯកសារសំរាប់ហ្វឹកហ្វឺនក្របខ័ណ្ឌជាតិផ្នែកឯកទេសនៃប្រព័ន្ធសន្សំសំចៃ និង ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ ដើម្បីជួយប្រតិបត្តិករ និង អនាគតវិជ្ជាស្ថាន ផ្នែកឥណទានព្រមទាំងបំរើការក្នុងរដ្ឋបាលដែលពាក់ព័ន្ធវិស័យនេះ ។

ខ-គ្រប់គ្រងការប្រើប្រាស់ឥណទានជនបទអោយមានប្រសិទ្ធភាពដោយ :

-សំរបសំរួល និង តាមដានគ្រប់សកម្មភាពឥណទានសំរាប់អភិវឌ្ឍន៍ជនបទ ដើម្បីអោយការប្រើប្រាស់ឥណទានស្របតាមទិសដៅ និង ជៀសវាងការរង្គោះរង្គើរ និង រាំងស្ទះដល់ការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុជាតិ ។

-សំរបសំរួលមធ្យោបាយទាំងឡាយ ដែលរាជរដ្ឋាភិបាលផ្តល់អោយ ដើម្បីអនុវត្តអោយបានល្អនូវនយោបាយជាតិក្នុងវិស័យនេះ ។

គ-ជួយពង្រឹងផ្នែកស្ថាប័ន និង ជួយជំរុញប្រតិបត្តិករឯកជនដោយ:

-កត់សំគាល់ លើកកំពស់ និង គាំទ្ររាល់សកម្មភាពសន្សំសំចៃ និង ឥណទាន ដែលបំរើដល់ការអភិវឌ្ឍន៍ជនបទ និងបង្កើនជីវភាពប្រជាជនក្រីក្រ និង ជួយជំរុញប្រព័ន្ធហិរញ្ញវត្ថុជាតិអោយអាចបំពេញសេចក្តីត្រូវការលើការសន្សំ និង ឥណទាននៅទូទាំងប្រទេស ។

-លើកទឹកចិត្តប្រតិបត្តិករថ្មីតាមន័យដូចបានបញ្ជាក់ខាងលើ ដែលជួយផ្តល់ឥណទានបន្ថែមលើប្រតិបត្តិករដែលមានរួចហើយ ។

-ជួយរិះរកមធ្យោបាយផ្សេងៗ ដើម្បីជំរុញអោយមានការបង្កើតធនាគារពាណិជ្ជកម្មតាមខេត្ត ដែលអាចធ្វើប្រព័ន្ធ ហិរញ្ញវត្ថុអាចមានការងាយស្រួលក្នុងការផ្ទេ-ផ្ទេរមូលនិធិ គ្រប់គ្រងធនធានខ្លួនបាន និងជួយបង្កើតធនធានឥណទានសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ។

ឃ-រៀបចំកម្មវិធី និង ផែនការដើម្បីបង្កលទ្ធភាពងាយស្រួលក្នុងការគៀងគរ ជំនួយពី បរទេស សំរាប់គំរូវការឥណទាន ។

-កំណត់ទិសដៅ និង សំរបសំរួលជំនួយទ្វេភាគី និងពហុភាគីក្នុងវិស័យឥណទានជនបទ ។

មាត្រា ៥ : អង្គភាពបច្ចេកទេសរបស់ គជទាន មានភារកិច្ចដូចតទៅ :

-អនុវត្តការងារប្រចាំថ្ងៃរបស់ គជទាន

-រៀបចំរាល់សំណុំរឿងទាក់ទិននឹង គជទាន ដើម្បីដាក់ជូន គជទានពិនិត្យ និង អនុម័ត ។

-សំរបសំរួលការងារប្រតិបត្តិករទាំងអស់ ដែលប្រើប្រាស់ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ ។

មាត្រា ៦ : នាយក ក៏ដូចជាអង្គភាពបច្ចេកទេសត្រូវបានតែងតាំងឡើងសំរាប់រយៈពេលគ្រប់គ្រាន់ ដើម្បីបំពេញអាណត្តិក្នុងការ អភិវឌ្ឍន៍ឥណទានជនបទតាមកម្មវិធីផ្តល់ជំនួយ ។

មាត្រា ៧ : រាល់អនុក្រឹត្យ និង សេចក្តីសំរេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ : គជទាន និង រាល់ក្រសួង ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣១ អនក្រ
ស្តីពីការបំពេញបន្ថែមក្នុងប្រាក់បៀវត្សសំរាប់សារជាតិ
របស់មន្ត្រីរាជការ និយោជិក កម្មករ ប្រចាំឆ្នាំ ១៩៩៥

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-តាមសំណើរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តរជាតិ លេខ ៣២៥-៩៤ គបជអ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៤ ។

សំរេច

មាត្រា ១ : បំពេញបន្ថែមលើអនុក្រឹត្យ លេខ ០៣ អនក្រ ចុះថ្ងៃទី ០៥-០១-៩៥ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៥ នូវប្រតិទិនឈប់សំរាកការងារ មួយថ្ងៃ គឺ ÷

-ថ្ងៃទី ២៤ កញ្ញា បុណ្យខួប ឡើងគ្រងរាជសម្បត្តិនៃព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ នៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៤ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់ សមាគម ឥស្លាមកម្ពុជា

សំរេច

មាត្រា ១ ៖ ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ១ ជូនចំពោះសប្បុរសជន ដែលបានជួយសាងសង់វិហារឥស្លាមអន្តរជាតិ បឹងកក់ ដូចមានរាយនាមខាងក្រោមនេះ ៖

១-លោក **ទីុសាពិន ណារស្សៀរ**

២-លោក **ម៉ះម៉ូក អាប់ឌុលឆេ្សាះកាស៊ីម**

លោកទាំងពីរនេះ ជាជនជាតិសហភាពអារ៉ាប់អេមេរ៉ាត បានរួមគ្នាកសាងអស់ទឹកប្រាក់ ៤០០.០០០ ដុល្លារអាមេរិក ។

៣-**ប៉ាក់គោមី ហ៊ិញូស្សូ គ្រុប** នៃប្រទេសឥណ្ឌូណេស៊ី អស់ទឹកប្រាក់ ១២.៥០០ ដុល្លារអាមេរិក ។

មាត្រា ២ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

សេចក្តីសំរេចលេខ ១៥ សសរ
ស្តីពីការបង្កើតគណៈកម្មការរៀបចំ
កីឡាជនពិការកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-តាមសំណើសុំរបស់រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង រួមជាមួយអង្គការជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំទិវាកីឡាជនពិការកម្ពុជា ដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន	ប្រធាន
២-តំណាងក្រសួងអប់រំ យុវជន និង កីឡា	អនុប្រធាន
៣-តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	សមាជិក
៤-តំណាងក្រសួងមហាផ្ទៃ	សមាជិក
៥-តំណាងក្រសួងការពារជាតិ	សមាជិក
៦-តំណាងក្រសួងសុខាភិបាល	សមាជិក
៧-តំណាងក្រសួងវប្បធម៌	សមាជិក
៨-តំណាងក្រសួងព័ត៌មាន	សមាជិក
៩-តំណាងគណៈកម្មាធិការ បុណ្យជាតិ និង អន្តរជាតិ	សមាជិក
១០-តំណាងប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ	សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចចាត់ចែង និង រៀបចំ ទិវាកីឡាជនពិការកម្ពុជា អោយបានល្អប្រសើរ នៅអំឡុង ខែ មិនា ជារៀងរាល់ឆ្នាំ ។

ប្រការ ៣ : ប្រគល់ភារកិច្ច អោយគណៈកម្មការនេះ បង្កើតអនុគណៈកម្មការដែលចាំបាច់ដើម្បីដំណើរការ ទិវាកីឡាជនពិការ ។

ប្រការ ៤ : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមសេចក្ដីអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីសំរួលក្នុងការងារ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលប្រចាំ រាជធានីភ្នំពេញ ប្រធានគណៈកម្មការបុណ្យជាតិ និង អន្តរជាតិ ព្រមទាំងអង្គការទាំងអស់ ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្ត សេចក្ដីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ត លេខា និងចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ ១៦ សសរ

ស្ដីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមការងារចាំបាច់

សំរេច

ប្រការ ១ : ក្នុងឱកាសដែលឯកឧត្ដម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្ដម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអញ្ជើញទៅ

បំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃ ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ការងាររបស់ឯកឧត្តមទាំងពីរត្រូវបានផ្ទេរជូនឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រហូតដល់ពេលឯកឧត្តមទាំងពីរវិលត្រឡប់មកមាតុប្រទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **សុខ អាន** ត្រូវទទួលបន្ទុកអនុវត្តការកិច្ចនេះរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
រាណឫទ្ធិ នរោត្តម	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ១៧ សសរ
ស្តីពីការបង្កើតគណៈកម្មការចំរុះ
សំរាប់កិច្ចសហប្រតិបត្តិការ ខ្មែរ-ថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះ សហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស និងវប្បធម៌ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃរាជាណាចក្រថៃឡង់ដ៍ ដែលមានសមាសភាពដូចខាងក្រោម :

១_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ		ជាប្រធាន
២_តំណាងក្រសួងការពារជាតិ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៣_តំណាងក្រសួងមហាផ្ទៃ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៤_តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៥_តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៦_តំណាងក្រសួងផែនការ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៧_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៨_តំណាងក្រសួងពាណិជ្ជកម្ម	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៩_តំណាងក្រសួងអប់រំ យុវជន និង កីឡា	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១០_តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១១_តំណាងក្រសួងសុខាភិបាល	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១២_តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៣_តំណាងក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៤_តំណាងក្រសួងទេសចរណ៍	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៥_តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៦_តំណាងក្រសួងគ្រប់គ្រងបរិស្ថាន	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៧_តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៨_តំណាងធនាគារជាតិកម្ពុជា	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
១៩_តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
២០_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
២១_មន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ		ជាលេខាធិការ

ប្រការ ២ : គណៈកម្មការចំរុះនេះ មានភារកិច្ចដូចតទៅ :

- ពិភាក្សារៀបចំសំរបសំរួលខ្លឹមសារការងារដោយត្រូវកំណត់អាទិភាពច្បាស់លាស់សំរាប់ធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃរាជាណាចក្រថៃឡង់ដ៍
- ពិនិត្យសិក្សា ផ្តល់មតិ និងលើកវិធានការលើរាល់ឯកសារពាក់ព័ន្ធ ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

ប្រការ ៣ : សមាជិកទាំងអស់នៃគណៈកម្មការនេះត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិជាផ្លូវការ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍ អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

II- ការងារបណ្តាក្រសួង

១. ធីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០០៦ ប្រ.សហវ

ស្ដីពីការណែនាំអនុវត្តថវិកាឆ្នាំ១៩៩៥

ច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ១ ហើយបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។ ផ្អែកលើមូលដ្ឋាននៃច្បាប់នេះ គណៈរដ្ឋមន្ត្រីបានចេញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើប្រកាសលេខ ០០៤ សហវ.ថ ចុះថ្ងៃទី ២៦ ខែ ១ ឆ្នាំ ១៩៩៥ ស្ដីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រការកថាខ័ណ្ឌវាក្យខណ្ឌជូនបណ្ដាក្រសួង តាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ។

ដើម្បីអោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបានអនុវត្តប្រកបដោយលទ្ធផលល្អប្រសើរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥ ដូចខាងក្រោមនេះ:

សេចក្ដីប្រកាសលេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការណែនាំអនុវត្ត ថវិកាឆ្នាំ១៩៩៤ នៅតែរក្សាប្រសិទ្ធភាពអនុវត្តសំរាប់ឆ្នាំ ១៩៩៥ ដដែលដោយគ្រាន់តែធ្វើការបំពេញបន្ថែមនូវចំណុចមួយចំនួនដូចតទៅនេះ

I . អំពីចំណូលថវិកា :

១_អង្គភាពដែលមានចំណូលថវិកាជាប្រាក់រៀលឬរូបិយប័ណ្ណ បរទេសត្រូវយកទៅបង់ផ្ទាល់និងជាបន្ទាន់នៅរតនាគារដែលបោះទីតាំងនៅទីនោះ ដោយភ្ជាប់មកជាមួយនូវសាលាកប័ត្រចំណូលថវិកាដែលបានកត់ត្រាត្រឹមត្រូវទៅតាមអត្ថន័យចំណូលថវិកា (Lanature de la recette bugetaire) នៃមាតិកាថវិកា ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសផ្សព្វផ្សាយ ។

២_ប្រាក់ចំណូលរបស់រដ្ឋ ត្រូវតែយកទៅបញ្ចូលក្នុងរតនាគារទាំងអស់ ហើយអង្គភាពមិនត្រូវមានការកាត់កងឬខ្ចីលើប្រាក់ចំណូលនោះទេ ដោយសំអាងទៅលើការចំណាយរបស់ខ្លួនក្នុងការប្រមូលប្រាក់ទាំងនោះក្នុងនាមរដ្ឋ ពីព្រោះចំណូលរបស់រដ្ឋទាំងអស់គឺយកទៅប្រើប្រាស់សំរាប់ទប់ទល់នឹងការចំណាយ របស់រដ្ឋទាំងអស់ ។

II . អំពីចំណាយថវិកា :

ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ គឺជាថវិកានៃការខិតខំប្រឹងប្រែងនិងជាថវិកាមានការត្បិតត្បៀត ។ ខិតខំប្រឹងប្រែងប្រមូលធនធានក្នុងប្រទេស ដើម្បីបង់ចូលរដ្ឋហើយ ត្បិតត្បៀតក្នុងការចំណាយ សំរាប់ការប្រព្រឹត្តទៅនៃកិច្ចការរដ្ឋបាលសាធារណៈ ។ នៅក្នុងឆមាសទី ១ នេះចំណូលក្នុងប្រទេសមានជាកំរិត រីឯចំណូលមូលធនសំរាប់ទ្រទ្រង់ថវិកាក៏មាន ជាកំរិតដែរជាពិសេសនៅត្រីមាសទី ២ ស្ទើរតែគ្មាន ដូច្នេះ ការចំណាយត្រូវផ្តល់អាទិភាពមុនគេ គឺប្រាក់បៀវត្ស គោលនយោបាយសង្គមកិច្ចការចំណាយចាំបាច់របស់រដ្ឋការចំណាយសំរាប់វិនិយោគ

ចំណែកឯចំណាយផ្សេងៗទៀតត្រូវតែកំណត់នៅក្នុងកំរិតទាបបំផុត ។

ដើម្បីអនុវត្តអោយបានត្រឹមត្រូវតាមទិសដៅវិធានការណ៍ខាងលើ នេះការផ្តល់ចំណាយជាក់ស្តែងត្រូវគោរពទៅតាមគោលការណ៍ដូចតទៅ :

១_ការចំណាយសំរាប់ប្រាក់បៀវត្ស ត្រូវបើកផ្តល់ប្រចាំខែអោយបានទាន់ពេលវេលានិងត្រូវអនុវត្តអោយបានត្រឹមត្រូវតាមចំនួនមន្ត្រី រាជការ ដែលបានកំណត់នៅក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។ ហើយព្រមជាមួយនេះ ត្រូវអនុវត្តអោយបានត្រឹមត្រូវ

ទៅតាមសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ ប្រ.ក ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការកែទំរង់រដ្ឋបាលសាធារណៈ ដែលតម្រូវអោយបើកប្រតិបត្តិការរាប់ចំនួនមន្ត្រីរាជការ ចាប់ពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ តទៅ ។ បន្ទាប់ពីប្រតិបត្តិការនេះនឹងមានការជំរឿនដ៏ពេញលេញ ទូទាំងប្រទេសដើម្បី :

+ លុបបំបាត់អនិយតភាពដែលមានសព្វថ្ងៃ ជាពិសេស :

-ចំនួនមន្ត្រីរាជការក្នុងបញ្ជីបើកប្រាក់បៀវត្សមានលើសពីចំនួនពិតប្រាកដ

-មនុស្សតែម្នាក់ធ្វើការក្នុងស្ថាប័នច្រើនកន្លែង

-ការមិនគោរពតាមនីតិក្រមចូលនិវត្តន៍

-ការយកអត្រានុកូលដ្ឋានរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន

+គ្រប់គ្រងអោយបាននូវចំនួនពិតប្រាកដនៃមន្ត្រីរាជការដែលកំពុងមានសកម្មភាពជាក់ស្តែង ក្នុងស្ថាប័នរដ្ឋនិមួយៗ ។

២-ការផ្តល់ប្រាក់ចំណាយសំរាប់ដំណើរការរដ្ឋបាល សំភារៈនិងជួសជុលតូច ត្រូវគោរពទៅតាមនិតិវិធីហិរញ្ញវត្ថុអោយបានត្រឹមត្រូវមានឯកសារស្របច្បាប់ភ្ជាប់តាមជាមួយ ដូចជាវិក័យប័ត្រ គំរោងចំណាយលំអិត កំណត់ហេតុពិគ្រោះថ្លៃ....... ។ល។ បើការចំណាយនោះលើសពី ១០ លានរៀលត្រូវមានកំណត់ហេតុដេញថ្លៃត្រឹមត្រូវ " ទៅក្រសួងស្ថាប័នរដ្ឋបាលកណ្តាលត្រូវមានការចូលរួមពីមន្ត្រីរាជការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅខេត្ត-ក្រុង ត្រូវមានការចូលរួមពីមន្ត្រីរាជការមន្ទីរហិរញ្ញវត្ថុ " ។

មិនអនុញ្ញាតអោយផ្តល់តាមរបៀប គិតជាបញ្ញើកាតឬផ្តល់ជាបណ្តោះអាសន្ន ប្រចាំខែដោយ ផ្អែកទៅតាមឥណទានដែលបានកំណត់នៅក្នុងសៀវភៅថវិកានោះទេ ។

៣-ការផ្តល់ប្រាក់ចំណាយសំរាប់មន្ត្រីឃុំ សង្កាត់និងភូមិ ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមអនុក្រឹត្យលេខ ២៧ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ឆ្នាំ ១៩៩៤ របស់គណៈរដ្ឋមន្ត្រី ស្តីពីការកំណត់របបប្រាក់ឧបត្ថម្ភចំពោះមន្ត្រីឃុំ-សង្កាត់និងភូមិ ។ នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ គណៈរដ្ឋមន្ត្រីបានចេញអនុក្រឹត្យ បែងចែកឥណទាន សំរាប់ឧបត្ថម្ភខេត្ត-ក្រុង

"សំរាប់ចំណាយជាគុណប្រយោជន៍ខេត្ត-ក្រុង" មាននៅក្នុងជំពូក ១២ នៃក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ និងនៅជំពូក ១២ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូច្នេះ រាល់ការចំណាយត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៤_ចំពោះការចំណាយសំរាប់គោលនយោបាយសង្គមកិច្ច ត្រូវបើកផ្តល់ប្រចាំខែអោយបានទាន់ពេលវេលា ហើយត្រូវផ្អែកលើចំនួនដែលមានពិតប្រាកដ ។ នៅពេលបើកប្រាក់ឧបត្ថម្ភគោលនយោបាយសង្គមកិច្ចនេះម្តងៗ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមជាមួយអធិការដ្ឋានសង្គមកិច្ចការងារ និងអតីតយុទ្ធជន ដើម្បីត្រួតពិនិត្យ ចំនួនតាមមុខសញ្ញាសង្គមកិច្ចអោយ បានជាប្រចាំ ។

៥_ក្នុងឆ្នាំ ១៩៩៥ នេះ ការចំណាយសំរាប់វិនិយោគស្ថាបនាមូលដ្ឋាន ត្រូវបានធ្វើការកែប្រែចំណាត់ថ្នាក់ទៅតាមប្រភពហិរញ្ញប្បទានដូចតទៅ ៖

+ជំពូក ៥០ ៖ វិនិយោគដោយហិរញ្ញប្បទាន ក្នុងប្រទេសមានពីរប្រភេទ ៖

-ប្រការ ០១ : ឥណទានសាងសង់និងទព្វសំភារៈ

-ប្រការ ០២ បដិភាគជារូបិយវត្ថុ ក្នុងប្រទេសនៃហិរញ្ញប្បទានផ្ទាល់ពីក្រៅប្រទេស ឥណទានសាងសង់និងទព្វសំភារៈ ៖

នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ឥណទានសាងសង់ និងទព្វសំភារៈ ត្រូវបានធ្វើការគ្រប់គ្រងនិងបែងចែកដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ដើម្បីអោយការបែងចែកឥណទានសាងសង់ និង ទព្វសំភារៈប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ក្រសួងស្ថាប័នសាធារណៈប្រហាក់ប្រហែលទាំងអស់ ត្រូវធ្វើសំណើសុំឥណទានសាងសង់និង ទព្វសំភារៈមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវគំរោងសាងសង់ទាំងមូល ដែលមានបញ្ជាក់ពីអត្ថប្រយោជន៍ឬទព្វសំភារៈដែលត្រូវបំពាក់និងចណ្តាំងកសារបច្ចេកទេសដូចជាគំរោងប្លង់គំរោងចំណាយលំអិត .... និងត្រូវបំពេញសលាកប័ត្រដូចមានគំរូឧបសម្ព័ន្ធ ភ្ជាប់នឹងសេចក្តីប្រកាសនេះ ។

បដិភាគជារូបិយវត្ថុក្នុងប្រទេសនៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់គឺជាឥណទានដែលរួមចំណែកជាមួយគំរោងវិនិយោគក្រៅប្រទេស មាន ៣ ភាគរយ ៥ ភាគរយ ឥណទាននេះអាចអនុវត្តបាន

ក្រោយពីមានកិច្ចព្រមព្រៀងលើគំរោង វិនិយោគក្រៅប្រទេស រវាងម្ចាស់ជំនួយ និង សាមីក្រសួង និមួយៗ ហើយ ។

+ជំពូក ៥១ ៖ វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ៖

ទុនវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ត្រូវបានកត់ត្រានៅក្នុងថវិកាគ្រាន់តែក្នុងនាមជាការចង្អុលបង្ហាញអោយក្រសួងនីមួយៗធ្វើការទាក់ទងដោយផ្ទាល់ជាមួយបណ្តាប្រទេសឬអង្គការអន្តរជាតិដែលជាអ្នកផ្តល់ជំនួយដល់កម្ពុជាពីព្រោះឥណទានកត់ត្រាក្នុងថវិកាប្រភេទនេះ ពុំអាចប្រើប្រាស់ផ្ទាល់បានដោយអាណាប័កឡើយ ឥណទាននេះមានលក្ខណៈប៉ាន់ស្មាន ហើយពុំអាចធ្វើការកម្មវត្ថុនៃនិយ័តភាពណាមួយទៅជំពូកថវិកាផ្សេងៗទៀតបានឡើយ ។ ឥណទាននេះ ទុកសំរាប់ឆ្លុះបញ្ចាំងក្នុងគណនីសាធារណៈ ក្នុងលក្ខណៈនៃនិយ័តភាពវិនិយោគ ដែលត្រូវអនុវត្តដោយអ្នកផ្តល់ ហើយចំណូលនៃជំនួយទាំងនោះឥតឆ្លងកាត់តាមរតនាគារឡើយ ។

III. អំពីចលនាឥណទានថវិកា ៖

១-ក្រសួង ស្ថាប័នសាធារណៈប្រហាក់ប្រហែលនិងខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានរបស់ខ្លួនតាមច្បាប់ស្តីពីហិរញ្ញវត្ថុ ដែលបាន អនុញ្ញាតិ ។ ក្នុងករណីខ្វះចំណាយណាមួយខ្លះឬគ្មានតែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពពីខ្ទង់ចំណាយដទៃទៀតរបស់ អង្គភាពខ្លួនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ សំរេច ។

២-ក្រសួងនិមួយៗឬស្ថាប័នសាធារណៈប្រហាក់ប្រហែលនិមួយៗមានសំណូមពរចាំបាច់ចង់ផ្ទេរឥណទានរបស់ខ្លួនបន្ថែមទៅអោយមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុងឬផ្ទុយវិញឬចង់ផ្ទេរឥណទានពីមន្ទីរជំនាញរបស់ខ្លួនពីខេត្ត-ក្រុង មួយទៅខេត្ត-ក្រុងមួយ ទៀតត្រូវធ្វើសំណើសុំ ផ្ទេរឥណទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យសំរេច ដោយមានការឯកភាពពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអភិបាលខេត្ត-ក្រុង ។

៣-ក្រសួងឬស្ថាប័នសាធារណៈប្រហាក់ប្រហែលមានឥណទានជំពូក ៥០ ហើយចង់បែងចែកឥណទាននោះទៅអោយមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុងប្រើប្រាស់នោះ ត្រូវធ្វើ សំណើ

សុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើប្រកាសផ្ទេរជូនតែមិនអនុវត្តការធ្វើបញ្ញា ចំណាយ ជូនដូចមុនទេ ក្រោយពីបានគោរព បែបបទនិតិវិធីហិរញ្ញវត្ថុ ត្រឹមត្រូវហើយ ។

_ថវិការដ្ឋឆ្នាំ ១៩៩៥ នៅជួបការលំបាកយ៉ាងច្រើនអាស្រ័យដោយសភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមមិនទាន់បានរៀបរយល្អ ធ្វើអោយការប្រមូលចំណូលពុំអាចអនុវត្ត បាន អស់លទ្ធភាពដែលមានទន្ទឹមនោះគ្រោះទឹកជំនន់និងរាំងស្ងួតក្នុងឆ្នាំ ១៩៩៤ បានជះឥទ្ធិពល យ៉ាងខ្លាំងដល់ ការចំណាយថវិកាក្នុងឆ្នាំ ១៩៩៥ សំរាប់ស្តារនិងជួសជុលឡើងវិញនូវការខូចខាត ទាំងឡាយដូច្នេះក្នុងឆ្នាំ ១៩៩៥ នេះគ្រប់ក្រសួងគ្រប់ផ្នែក ត្រូវយកចិត្តទុកដាក់អនុវត្តការសន្សំសំចៃ អោយបានម៉ឺងម៉ាត់បំផុត ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គាត ឈន់

***

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ០០៦
ថវិកាឆ្នាំ ១៩៩៥
ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស

ការរាយមុខគំរោង

: ....

លេខគំរោង

: ឆ្នាំ / លេខ..

រយៈពេលការងារដែលត្រូវធ្វើ : ....

....

កត់ត្រាចំណាយផេរិកា : ....

សេចក្តីបង្ហាញជាសង្ខេបនៃគំរោង : ....

វិភាគអំពីផលលាភិយភាព (ខាងសេដ្ឋកិច្ច) ឬអំពីប្រយោជន៍ (ខាងសង្គមកិច្ច) នៃគំរោង

ប៉ាន់ស្មានគំរោងទាំងមូល : ចំណាយសរុប : ....

ចែកជាដំហាន ៗ តាមឆ្នាំ :

ឆ្នាំទី ១	ឆ្នាំទី ២	ឆ្នាំទី ៣	ឆ្នាំទី ៤	ឆ្នាំទី ៥	សរុប

បញ្ជីឥណទានប្រតិទាន " បញ្ជីថ្លៃសងបំណុល " តាមឆ្នាំ

ឆ្នាំទី ១	ឆ្នាំទី ២	ឆ្នាំទី ៣	ឆ្នាំទី ៤	ឆ្នាំទី ៥	សរុប

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សេចក្តីប្រកាសអន្តរក្រសួងលេខ ០៤១ ប្រក ស្តីពីការអនុញ្ញាតិអោយសាធារណជនដូរ ក្រដាសប្រាក់រៀលដែលចរាចរមិនកើត

ដើម្បីរក្សាបាននូវផលប្រយោជន៍របស់ពលរដ្ឋ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាននៅសល់ក្រដាសប្រាក់ចាប់ពីប្រភេទ ប្រាំរៀល ដប់ ហាសិបរៀលនោះ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ សូមចេញសេចក្តីប្រកាស អន្តរក្រសួងជូនសាធារណជនជ្រាបដូចខាងក្រោម :

១_កាស និងក្រដាសប្រាក់ពីមួយរៀលចុះទៅ រដ្ឋបានដកចេញពីចរាចរ ចាប់តាំងពីខែ ៤ ឆ្នាំ ១៩៨៨ ហើយ ។ ក្រដាសប្រាក់រៀល ដែលមានចលនាជានិត្យានុកូលសព្វថ្ងៃនេះ គឺក្រដាសប្រាក់មានតម្លៃ ចាប់តាំងពីប្រាំរៀលឡើងទៅ ។

២_ក្រដាសប្រាក់ប្រាំរៀល ដប់រៀល ម្ភៃរៀល និងហាសិបរៀល ដែលចរាចរមិនកើត ឬពិបាកចរាចរនោះ ត្រូវបានអនុញ្ញាតិអោយដូរ តាមការជាក់ស្តែងដើម្បីយកក្រដាសប្រាក់មានតម្លៃខ្ពស់ជាង ក្នុងគោលគំនិតនេះសំដៅជួយប្រជាពលរដ្ឋអោយជៀសវាងនូវការខាតបង់ ។

៣_នៅតាមបណ្តាខេត្ត-ក្រុង មន្ត្រីរាជការរតនាគារ និងធនាគារឯកទេស ក្រោមឱវាទធនាគារជាតិត្រូវសហការគ្នាអោយបានជិតស្និទ្ធបំផុត ក្នុងការដោះដូរប្រាក់នេះ ។

នៅក្នុងរាជធានីភ្នំពេញ បន្ទុកដោះដូរនេះត្រូវអនុវត្តដោយ :

- ធនាគារឯកទេសរាជធានីភ្នំពេញ
- ធនាគារពាណិជ្ជកម្មក្រៅប្រទេស
- រតនាគារជាតិ
- អគ្គបេឡា នៃធនាគារជាតិ

បើខ្វះសាច់ប្រាក់ ឬបើប្រាក់ប្រភេទតូច ដែលប្រមូលបានមានបរិមាណច្រើន ពិបាកក្នុងការដឹកជញ្ជូន ត្រូវទំនាក់ទំនងជាមួយអគ្គបេឡា ធនាគារជាតិ នៃកម្ពុជា ភ្លាម ដើម្បីដោះស្រាយ ។

៤-មន្ត្រីរាជការណា ដែលបានប្រព្រឹត្តអំពើខុសឆ្គង ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលជាហេតុនាំអោយប្រជាពលរដ្ឋខាតបង់ ឬបង្កលក្ខណៈលំបាកក្នុងការប្តូរ ឬធ្វើអោយតម្លៃពិតទាបជាងតម្លៃចារិកលើកក្រដាសប្រាក់ទោះជាតាមរូបភាពណាក៏ដោយ និងត្រូវព្យួរមុខតំណែងភ្លាម ទំរាំចាត់វិធានការរដ្ឋបាល ដែលមានរហូតដល់ធ្វើអវិរុទ្ធកម្ម និងបញ្ជូនទៅ តុលាការរោនសមត្ថកិច្ច ដើម្បីជំនុំជំរះ ។

៥-សេចក្តីប្រកាសអន្តរក្រសួងនេះ ជាលិខិតប្រគល់សិទ្ធិប្រទាន របស់ហត្ថលេខី ខាងក្រោមនេះ : ជូននាយកដ្ឋានចាត់តាំង ធនាគារជាតិ នៃ កម្ពុជា និង នាយកដ្ឋានបុគ្គលិក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់រាជធានីភ្នំពេញ និងជូនអភិបាលខេត្ត-ក្រុង សំរាប់ខេត្ត-ក្រុង ឯទៀត ដើម្បីអនុវត្ត ភ្លាមនូវការព្យួរតំណែងមន្ត្រីដែលបានប្រព្រឹត្ត បទល្មើសដូចមានក្នុងចំណុច ៤ ខាងលើ ។

៦-គ្រប់នាយកដ្ឋាន និងស្ថាប័នទាំងអស់ ដែលនៅក្រោមឱវាទធនាគារជាតិ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តសេចក្តីប្រកាសអន្តរក្រសួងនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រី
ក្រសួងមហាផ្ទៃ
ហត្ថលេខា និង ត្រា
ស ខេង យូ ហុកគ្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

ទេសាភិបាល
ធនាគារជាតិ នៃ កម្ពុជា
ហត្ថលេខា និង ត្រា
ជា ចាន់តូ

***

២. ធីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១២ ឧឃ.ប្រក
ស្ដីពី ការផ្ទេរភារកិច្ច មន្ត្រី រាជការ

រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញប្រកាសលេខ ១៧០៣ ចត.ប្រក ចុះថ្ងៃទី ២៨-១១-១៩៩៤ ស្ដីពី ការប្រគល់ការគ្រប់គ្រងផលិតកម្មអាជីវកម្ម រោងចក្រអារឈើ ជ្រោយចង្វារ ជូនក្រុមហ៊ុនឯកជនគ្រប់គ្រង

-បានឃើញពាក្យសុំផ្លាស់របស់ លោក **គិច ចាន់ដារ៉ា** លោក **អោង សាម្ងន** និង លោក **សុក គេង** ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ ៖ ផ្ទេរភារកិច្ច មន្ត្រី រាជការ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក **គិច ចាន់ដារ៉ា** ពីប្រធានរោងចក្រ អារឈើជ្រោយចង្វារ អោយមកបំរើការងារនៅនាយកដ្ឋានបច្ចេកទេស ដោយរក្សាកាំប្រាក់បៀវត្សនៅដដែល

២-លោក **អោង សាម្ងន** ពីអនុប្រធានរោងចក្រ អារឈើជ្រោយចង្វារ អោយមកបំរើការងារនៅ នាយកដ្ឋាន ផែនការ ដោយរក្សាកាំប្រាក់បៀវត្សនៅដដែល

៣-លោក **សុក គេង** ពីប្រធានការិយាល័យ គណនេយ្យរោងចក្រ អារឈើ ជ្រោយចង្វារ អោយមកបំរើការងារនៅ នាយកដ្ឋាន គណនេយ្យ-ហិរញ្ញកិច្ច

ប្រការ ២ ៖ រាល់សេចក្ដីសំរេច លិខិតបង្គាប់ការ ពីមុនដែលមានចំណុចពាក់ព័ន្ធ និងអស់លោកដូចមានចែងក្នុងប្រការ ១ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ ៖ លោកប្រធានមន្ទីរ , ប្រធាននាយកដ្ឋានបុគ្គលិក , ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញកិច្ច , ប្រធាននាយកដ្ឋានផែនការ , ប្រធាននាយកដ្ឋានបច្ចេកទេស , គណៈកម្មាធិការត្រួតពិនិត្យ និង អស់លោកទាំង ០៣ រូប ខាងលើមានភារកិច្ចអនុវត្ត ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ។

ប្រការ ៤ ៖ ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេតចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៤២០ រៀល